នាយកដ្ឋានបុគ្គលិក
លេខ ១០៤
ចូលថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២១
ម៉ោង ០៣ : ៣០
បញ្ជូនទៅ ការិ - បុគ្គលិក

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
នាយកដ្ឋានរដ្ឋបាលទូទៅ
ចូល
លេខ ១១
ថ្ងៃទី ២៨ ខែ ០១ ឆ្នាំ ២១
ម៉ោង ១៤:០០

# ព្រះរាជក្រឹត្យ

## ស្ដីពី

នស/រកត/០១២១/ ០៤៤

## ការកែសម្រួលមាត្រា៩ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៤ មាត្រា៣២ និងមាត្រា៥១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## គ្រាស់បទ្ទាប់

**មាត្រាមួយ.-**

មាត្រា៩ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៤ មាត្រា៣២ និងមាត្រា៥១ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានកែសម្រួលដូចតទៅ ៖

**មាត្រា៩.-ថ្មី**

អ.គ.ជ.ប ក្នុងក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ មានមុខងារសម្រាប់កាន់មុខតំណែងជាអ្នកដឹកនាំ គ្រប់គ្រង អធិការកិច្ច សវនកម្ម បណ្ដុះបណ្ដាល សិក្សាស្រាវជ្រាវ ផ្ដល់យោបល់គោលនយោបាយ ផែនការ និងមុខងារក្នុងរាល់មុខតំណែងទទួលខុសត្រូវ ។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអគ្គលេខាធិការ អគ្គលេខាធិការរង អគ្គនាយក និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិវរមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអគ្គនាយករង ប្រធាននាយកដ្ឋាន និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ។

អ.គ.ជ.ប ក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ប្រធាន លធ.ខប និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ។

មុខតំណែង និងការពិពណ៌នាអំពីលក្ខខណ្ឌការងារនៃ អ.គ.ជ.ប ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប នឹងត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប ។

**មាត្រា១៣.-ថ្មី**

ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់បោះឆ្នោត ប្រាក់ឧបត្ថម្ភប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ប្រាក់វិភាជន៍គ្រួសារ ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗនៃ អ.គ.ជ.ប ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប អនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធន រួមនឹងបែបបទ និងនីតិវិធីនៃការដាក់ អ.គ.ជ.ប ឱ្យចូលនិវត្តន៍ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមានសម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ រហូតដល់ពេលមានលិខិតបទដ្ឋានគតិយុត្តថ្មីដែលអនុលោមតាមច្បាប់ស្ដីពីរបបសន្តិសុខសង្គមមកជំនួស ។



**មាត្រា១៨.-ថ្មី**

ការប្រឡងចូលក្របខ័ណ្ឌណាមួយ គ.ជ.ប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៧- អ.គ.ជ.ប ២ (ពីរ) នាក់ក្នុងក្របខ័ណ្ឌជាមួយ | សមាជិក ។ |

**មាត្រា២២.-ថ្មី**

ការតាំងស៊ប់ត្រូវសម្រេចក្នុងរយៈពេលមិនលើសពី ៣ (បី) ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ។

ការតាំងស៊ប់ចាប់ផ្ដើមមានប្រសិទ្ធភាពខាងផ្នែកបៀវត្ស ក៏ដូចជាអតីតភាពការងារសម្រាប់ឡើងថ្នាក់ ។ ប៉ុន្តែអតីតភាពការងារសម្រាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីពេលចាប់ផ្ដើមធ្វើកម្មសិក្សា ។ ការតាំងស៊ប់ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្ដល់យោបល់ពីគណៈកម្មការវាយតម្លៃមួយដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៧- អ.គ.ជ.ប ២ (ពីរ) នាក់ក្នុងក្របខ័ណ្ឌជាមួយ | សមាជិក ។ |

**មាត្រា២៤.-ថ្មី**

អ.គ.ជ.ប ណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍ ត្រូវបានចាត់ទុកថាបាត់បង់សមត្ថភាពការងារ ហើយត្រូវបញ្ឈប់មិនឱ្យធ្វើការតទៅទៀត ។

ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ធានារ៉ាប់រងសង្គមម្ដងគត់ និងប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍ ។ បើ អ.គ.ជ.ប នោះមានអតីតភាពការងារលើសពី ២០ (ម្ភៃ) ឆ្នាំ សាមីជនត្រូវបានតម្រូវឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ដោយទទួលប្រាក់សោធននិវត្តន៍សមាមាត្រ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៧- គ្រូពេទ្យដែលបានទទួលសញ្ញាប្រណិធាន និងដែលត្រូវបានចាត់តាំងដោយក្រសួងសុខាភិបាល | សមាជិក |
| ៨- អ.គ.ជ.ប ដែលមានក្របខ័ណ្ឌជាមួយគ្នា ១ (មួយ) នាក់ ដែលមានឋានន្តរស័ក្តិយ៉ាងហោចណាស់ស្មើនឹងសាមីជន | សមាជិក ។ |

**មាត្រា៣២._ថ្មី**

អគ្គលេខាធិការបញ្ជប់បញ្ជី អ.គ.ជ.ប ដែលត្រូវបានស្នើពិនិត្យដំឡើងថ្នាក់ រួចបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ដើម្បីធ្វើការប្រជុំ ។

សមាសភាពគណៈកម្មការដំឡើងថ្នាក់មានដូចខាងក្រោម ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៧- អ.គ.ជ.ប ២ (ពីរ) នាក់ក្នុងក្របខ័ណ្ឌជាមួយ | សមាជិក ។ |

**មាត្រា៥១._ថ្មី**

ប្រធាន គ.ជ.ប អនុប្រធាន គ.ជ.ប និងសមាជិក គ.ជ.ប អាចចាត់តាំងមន្ត្រីមួយចំនួនឱ្យធ្វើជាជំនួយការផ្ទាល់ ទោះបីសាមីជននោះពុំមែនជាមន្ត្រីក្របខ័ណ្ឌក៏ដោយ ។ ក្នុងករណីនេះ សាមីជនដែលទទួលការតែងតាំងមានសិទ្ធិទទួលប្រាក់បំណាច់ជាធម្មតា ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមអាណត្តិរបស់ គ.ជ.ប ។

**មាត្រាពីរ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២១

ពរសថ-២១០១-០៤៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**